# កង្វះរូបភាព

## សេណារីយ៉ូ ភាសាខ្មែរ




ការបញ្ចូលសម្លេងជាភាសាខ្មែរ ផលិតដោយ

មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញ និងទទួលការផលិតភាពយន្តនៅកម្ពុជា

Khmer adaptation and dubbing produced by the

Cambodia Film Commission

**Adaptation & Dubbing supervisor:**
Sophea Kim

**Translation/Adaptation:**
Rattan Lach,Puch Be, Sophea Kim

1 – Sur les apsaras qui dansent

ឈានដល់ពាក់កណ្តាលជីវិត
កុមារភាពរបស់ខ្ញុំក៏បានត្រលប់មកវិញ
វាហាក់បីដូចជាទឹកសាប
ប៉ុន្តែល្វីងជូរចត់

កុមារភាពរបស់ខ្ញុំ, ខ្ញុំរំលឹកវាឡើងវីញ
ដូចជាការស្វែងរករូបភាពដែលបាត់បង់ទៅ
ឬក៏អាចនិយាយបានថា
រូបភាពនោះ ស្រែកហៅខ្ញុំអោយតាមរកវា
តើនេះដោយសារ
វ័យ ៥០ឆ្នាំ របស់បានមកដល់?
រឺ មកពីខ្ញុំបានស្គាល់សម័យរឹករ
ដែលជាសម័យកាលមួយ គួរអោយព្រឺខ្លាច
និងក្តីសង្ឃឹម?

ឥឡូវ អនុស្សាវរីយ៍ទាំងនោះ កំពុងនៅទីនេះ
វាធ្វើអោយខ្ញុំឈឺចាប់ក្នុងខួរក្បាល
ខ្ញុំចង់បណ្តេញវាទៅអោយឆ្ងាយ

2 – Sur Mains du sculpteur qui fabriquent la figurine du père de Rithy Panh

ជាមួយ ដីនឹងទឹក
ជាមួយសាកសព, ដីស្រែ
ជាមួយដៃដែលនៅមានជីវិត
យើងបង្កើតរូបមនុស្ស
យើងពុំត្រូវការអ្វីច្រើននោះទេ
អោយតែមានចិត្ត គឺគ្រប់គ្រាន់ទៅហើយ

ខោអាវធំរបស់គាត់មានពណ៌ស, ក្រវ៉ាត់កពណ៌ក្រម៉ៅ
ខ្ញុំចង់អោបគាត់អោយជាប់នឹងដើមទ្រូងរបស់ខ្ញុំ
គឺជាឪពុករបស់ខ្ញុំ

3 – Sur maquette maison de Rithy Panh
ខ្ញុំចាំបានពីអតីតកាល
នៅទីក្រុងភ្នំពេញ
កម្មវិធីបុណ្យធំៗជាច្រើន
នៅផ្ទះរបស់យើង
ខ្ញុំចាំបានពីសំណើច និងចំរៀង
មានទាំងពីក្លិនស្កតាំងម៉ែ, ក្លិនត្រី,
គ្រឿងទេស, និងក្លិនស្វាយទុំ
ពួកយើងរាំ
យើងជជែកគ្នាពីនេះពីនោះមិនចេះចប់ជាមួយ សាច់ញាតិមីងមា
បងប្អូនជីដូនមួយយក ផ្លែមាន ផ្លែខ្នុរ និង ផ្លែឈើផ្សេងទៀតមកញ៉ាំជុំគ្នា

Silence – Intérieur maison
ពេលនោះជាពេលវេលានៃកាសិក្សា និងសៀវភៅ
ខ្ញុំចូលចិត្តកំណាព្យដែល ឪពុកអានអោយពួកយើងស្តាប់នៅពេលយប់

ជាពិសេសគឺភាពទន់ភ្លន់របស់គាត់

4 – Sur archives de la guerre/femmes qui supplie…
ក្រោយមកសង្គ្រាមក៏បានមកដល់
ការទំលាក់គ្រាប់បែកបានខិតកាន់តែជិត
នៅក្នុងអំឡុងឆ្នាំ ១៩៧០
ខ្ញុំនៅចាំបានពីមនុស្សដែលត្រូវបានស្លាប់ជាលើកដំបូង

ពីការភ័យខ្លាចរបស់ពួកយើង
និងពីទុក្ខព្រួយរបស់ខ្ញុំ

វាមានរូបភាពជាច្រើន
ដែលបង្ហាញ
និងបង្ហាញឡើងវិញ
នៅក្នុងពិភពលោក
ធ្វើអោយជឿថា វាជារបស់យើង
ព្រោះយើងបានឃើញរូបភាពនោះ ជាច្រើនដង ច្រើនសារ

រូបភាពមួយដែលយើងឃើញ
នៅលើអេក្រង់
ដែលមិនមែនជាក្តាខៀន
ក្រណាត់រុំសាកសពមនុស្ស
រូបភាពនោះ និងមិនបាត់បង់ទេ។

5 – Sur archives Khmer rouge/figurines Khmères rouges
ទីក្រុងភ្នំពេញ
ត្រូវបានហ៊ុំពទ្ធ័ដោយទាហានខ្មែរក្រហម
ដែលមកបញ្ចប់
ភាពអយុត្តិធម៌ និងការជិះជាន់។

ពួកគេបានចូលដល់រាជធានី ថ្ងៃទី ១៧ មេសា ឆ្នាំ ១៩៧៥
ពេលនោះសម្រែកនៃភាពរីករាយ ពុំមានទេ
ប៉ុន្តែជំនួសមកវិញ នូវការរង់ចាំដ៏ ស្ងាត់ជ្រងំ

ខ្ញុំនៅទីនោះ

ខ្ញុំនឹកឃើញពីក្រសែភ្នែក
របស់ទាហានប្រយុទ្ធក្មេងៗ
ដែលមើលមកយើងដូចមិនមែនជាមនុស្ស

ពួកគេបានចេញបញ្ជា៖ មិនអោយប៉ះពាល់ខ្មាំងដោយដៃ
ខ្មាំងនោះ
គឺខ្ញុំ
ដែលមានអាយុ ១៣ ឆ្នាំ។

6 – Sur archives ville vide

ធនាគារជាតិ ត្រូវបានកំទេចជាមួយនឹងក្រដាស់ប្រាក់ហើររប៉ាត់រប៉ាយ
គ្មានទេការត្រលប់ក្រោយ

ទីក្រុងមិនស្អាតស្អំ
ទីក្រុងពុករលួយ៖
ទីក្រុងនេះគ្មានអ្វីនៅសេសសល់ត្រឹមតែប៉ុន្មានម៉ោងប៉ុណ្ណោះ

- Sur archives intérieur maison
ប្រជាជនប្រមាណ ២ លាននាក់ត្រូវគេបណ្តេញអោយនៅលើផ្លូវ
ហើយបោះបង់ចោល,
ផ្ទះសម្បែង, ញាតិសណ្តាន, អនុស្សាវរីយ៍
និងជីវភាពដែលធ្លាប់រស់ពីមុន។

- Sur pano archives  Phnom Penh
ជយោមហាជោគជ័យ ថ្ងៃ៧ មេសា ដ៏រុងរឿង!

បដិវត្តន៍ស្អាតស្អំ ដែលមិនត្រូវការមនុស្ស
ឥឡូវនេះ គេអាចថតរូបភាពទីក្រុងភ្នំពេញ ដូចពុទ្ធទំនាយថា
មានផ្ទះអត់មនុស្សនៅ
មានផ្លូវអត់មនុស្សដើរ
មានជណ្តើរអត់មនុស្សឡើង
មានឈាមហូរដាបពោះដំរី។ ឃ្លោក លិច អំបែង អណ្តែត?

7 – Sur séquence de déportation de la famille/maquette
ត្រឹមមួយរំពេច ពួកយើងត្រូវបែកខ្ញែកគ្នា
ពួកយើងត្រូវបានជម្លៀសទីកាន់ជនបទ
ចំពេលរដូវប្រាំង។
យើងឃ្លានបាយ យើងស្រេកទឹក

យើង ត្រូវបានគេបញ្ជូន ពីកន្លែងមួយទៅមួយ
ដូចសត្វតិរច្ឆាន
ក្នុងទូរថភ្លើង រួចបន្តដោយរទេះគោ

8 -
ការជម្លៀសចេញពីក្រុងភ្នំពេញ ជារូបភាពដែលបាត់បង់។
Silence
– Sur plan fixe groupe/maquette
មិនយឺតយ៉ាវ ពួកទាហានខ្មែរក្រហមផ្តើមរាប់ចំនួនមនុស្ស
បន្ទាប់មកគេចែកអោយនៅដាច់ដោយឡែកពីគ្នារវាង ស្រ្តី បុរស
មនុស្សចាស់ និងកុមារ
ហាមដាច់ខាតរាល់វត្ថុអនុស្សាវរីយ៍, និងសំភារៈផ្ទាល់ខ្លួន
មួយពព្រិចភ្នែក គ្មានទេពាក្យថាមនុស្ស គឺមានតែលេខជំនួសមកវិញ

ពួកគេកាត់សក់របស់យើង
គេប្រមូលយក នាឡិការដៃ, វ៉ែនតា, របស់លេង, សៀវភៅ
សំលៀកបំពាក់របស់យើង ត្រូវគេជ្រលក់ពណ៌ខ្មៅ
គេប្តូរឈ្មោះរបស់យើង

យើងក្លាយជា ប្រជាជនថ្មី
អភិជន នាយទុន, បញ្ញវន្ត, ត្រូវបញ្ជូនទៅកសាងខ្លួន
ឬកំទេចចោល។

"មិត្តត្រូវលត់ដំខ្លួនអោយក្លាយជាវណ្ណៈអធន"

នេះហើយជារបបថ្មី ដែលគេហៅថា
កម្ពុជាប្រជាធិប្បតេយ្យ៖

រោងចក្រមានផ្សែងដំ
គួរអោយព្រួយបារម្ភ
ទំនប់ និងដីស្រែធ្វើអំពីបេតុង
តែគ្មានមនុស្ស!

9 – Sur archives chantier
សង្គមទាំងមូលត្រូវរៀបចំឡើងតាមរបៀបសហករណ៍ កងទព័ ដោយមានកំរិតការងាររៀងៗខ្លួន
"អង្គការយកចិត្តទុកដាក់លើមិត្តៗទាំងអស់គ្នា!"

ពុកម៉ែ បងប្អូន!

អង្គការជា

ទាំងអស់គ្នា
ម្នាក់ៗ
ជាយោធាខ្មែរក្រហមវ័យក្មេងៗ
ឬជាប្រធានភូមិ
ឬជាមេគុក នៃមន្ទីរទារុណកម្ម
ឬក៏ ប៉ុល ពត

ត្រូវតែតាមដាន ឃ្លាំមើល ពួកកម្មេចសំរាម
Silence

9 bis – Sur archives chantier
បន្តិចទៀត គ្មានទេមុខមាត់ជាមនុស្ស
គ្មានទេមិត្តភក្តិ
គ្មានទេស្នេហា
គ្មានឪពុក គ្មានម្តាយ
បន្តិចទៀត គ្មានទេមនោសញ្ចេតនា
ហើយសូម្បីតែពាក្យខ្លះក៏និងត្រូវកែប្រែ
ម្នាក់ៗនឹងក្លាយជាអ្នកប្រយុទ្ធដើម្បី បដិវត្តន៍
ឬក្លាយជាជីរសំរាប់ដីស្រែ

10 – sur les mains du sculpteur qui peint Rithy Panh
ដើម្បីរក្សាជីវិត
យើងត្រូវលាក់ខ្លួនឯង
លាក់កំលាំង
ប្រវត្តិ
និងគំនិតដែលគ្មានរណាម្នាក់អាចដឹង
ព្រោះគេអាចលួចយករូបរាងបាន

ប៉ុន្តែឧត្តមគតិគេមិនអាចលួចបានឡើយ

11– Sur maquette chantier
ឧអង្គការស្នើមិត្តទៅរៀនសូត្រ និងកសាងខ្លួន!à

មិត្ត!
មិនយូរមិនឆាប់ យើងនឹងក្លាយជាម្ចាស់ទឹក
ដី
និងអ្វីលើអ្វីៗទាំងអស់

បង្កើនផលស្រូវអោយបាន ៣ ឬ ៥ ឬ៧ តោន ក្នុងមួយហិចតា ក្នុងមួយឆ្នាំ

ប្រជាជននឹងកើនដល់ ១០ លាននាក់។

គ្មានទៀតទេ
ការអត់ឃ្លាន
គ្មានការនឿយហត់
គ្មានអំពើអយុត្តិអម៌

និងមានម៉ាស៊ីនបញ្ចុកបាយ មនុស្សចាស់ៗ

អង្គការមហាភ្លឺស្វាង មហាឈ្លាសវៃ!

ប្រជាជនជាខួរក្បាលរបស់អង្គការ។
ជយោបដិវត្តន៍កម្ពុជាដ៏មហាអស្ចារ្យ!
ជយោសង្គមថ្មីគ្មានអ្នកមានគ្មានអ្នកក្រ!

យើងលើកដៃប្ដេជ្ញាគ្រប់ៗគ្នា
និងសូត្រតាមពាក្យស្លោកទាំងនោះ។

12 – Sur maquette plongée chantier/hommes à vélos /hommes qui creusent/drapeau rouge

អង្គការរៀបចំសង្គមគំរូមួយ
មានតែមួយគត់ក្នុងលោក
ដោយមិនបែងចែកវណ្ណៈ។

នៅក្នុងពិភពដ៏ល្អឥតខ្ចោះ
ប្រឡាយទឹកធ្វើពីបេតុង
ទំនប់ក្រាលកៅស៊ូ
គ្រប់យ៉ាងត្រូវមានសណ្ដាប់ធ្នាប់

នៅលើកំពូលនៃបដិវត្តមហាលោតផ្លោះ
មានទង់ជាតិពណ៌ក្រហមដែលបង្ហាញថា៖ នេះហើយជាការពិត
មិត្ត! មិត្តមានសេរីភាពហើយ!

សំរាប់ម៉ោងនេះ
មិត្តត្រូវធ្វើតាមបញ្ជា
ប្រយុទ្ធមិនរាថយ
រែកដី
ជញ្ជូនថ្ម

អស់ពេលជាច្រើនខែ
ខ្ញុំបានជីកប្រឡាយនៅលើដីរឹងបែកក្រហែង

ខ្ញុំមិនដែលបានប្រទះឃើញទឹក, មិនដែលសោះ។

ឞជយោ!កម្ពុជាប្រជាធិបតេយ្យ មហាភ្លឺស្វាង មហាលោតផ្លោះ មហាអស្ចារ្យ!à។ ឞ

ឈរដាច់ខាតលើជំហារធ្វើស្រែដោយមិនពឹងផ្អែកលើមេឃ!à។

ពាក្យស្លោកទាំងនោះមិនព្រមចេញពីខ្ញុំទេ
នៅតែបន្លឺឡើងក្នុងត្រចៀកខ្ញុំ

Silence

13 – Collectivisme/maquette cantine

សង្គមចាស់មានតែភាពផ្ដើតផ្ដើន
សម្ងហភាព
ជាជីវជាតិ និងជាឆ្នាំងបាយ

ការមិនស្ដាប់បង្គាប់
ឆ្នាំងបាយមួយ ជាសញ្ញាបុគ្គលស្ងួនតួ
មិនត្រូវអោយមានជាដាច់ខាត
ដូច្នេះហើយ របស់របរត្រូវយកមកដាក់រួម
ទ្រព្យមួយគត់ដែលយើងមានសិទ្ធគឺ ស្លាបព្រាបាយ

ជាមួយការស្រេកឃ្លាន
អង្គការក្ដាប់មនុស្សម្នាក់, ក្ដាប់ទាំងអស់គ្នា
ទាំងអ្នកនៅរស់ និងអ្នកស្លាប់។

ឯអ្នកឈឺ
ឯអ្នកមិនស្ដាប់បញ្ជា

ពួកគេមិនអាចទទួលរបបអាហារ
ឬបានតែពាក់កណ្ដាលប៉ុណ្ណោះ

ការស្រេកឃ្លាន មានសម្រាប់ពួកយើង
ការស្រេកឃ្លាន ជាអាវុធ

ប្រជាជនថ្មី គឺជាពួកបញ្ញើក្អែក

ប្រជាជនចាស់ ជាអ្នកតាមដានពួកយើង
រស់នៅក្នុងជង្រុកស្រូវ ៖ គេមិនដែលស្គាល់ ភាពអត់ឃ្លាន

រៀនសូត្រឡើងវិញ គឺការកំទេចចោល

14 sur archives travelling avant rue vide

នៅភ្នំពេញ មានប្រជាជនដែលត្រូវបោសសំអាត។
ការដណ្ដើមយកទីក្រុងដោយការបណ្ដេញចេញ។ គឺជាមធ្យោបាយមួយសាមញ្ញបំផុត។

ខ្មែរក្រហមចង់បានមនុស្សចិត្តដែក ដែលជាឧបករណ៍របស់បដិវត្តន៍។
ពួកមេដឹកនាំខ្មែរក្រហមគឺជា៩ក្រុមសភាគធ្វើការរួមគ្នាà។

ពួកគេមិនដែលមើលបំណាំគ្នាឡើយ។ នេះប្រាកដជាប៉ុលពត បងធំទី១
ដែលយើងស្គាល់តាមរយះហ្វូងមនុស្សគាំទ្រ។ បន្ទាប់មកគឺមិត្តរួមអាវុធរបស់គាត់៖ នួន ជា ,
អៀង សារី , ខៀវ សំផន  និងសុន សេន។

15 sur maquette maison en desordre

៩ងើបឡើង អាពួកអម្ពល់ទុក្ខ!à។

ពួកអម្តល់ទុក្ខគឺពួកយើងដែលធ្វើការ ដូចទាសករ ត្រេចចរដូចខ្មោច។

រយៈពេលបួនឆ្នាំ ទីក្រុងខ្មោចគ្មានបន្សល់ទុកនូវអ្វីក្រៅពីមជ្ឈឹមបក្ស និងវិទ្យាល័យពញាយ៉ាត ដែលក្លាយជាគុកទួលស្លែងឡើយ។ នៅទីនោះ គេធ្វើទារុណកម្មមានដូចជា វាយដោយរំពាត់ខ្សែតី ឆក់ខ្សែភ្លើង អារក បញ្ច្រកលាមក ដើម្បីអោយអ្នកទោស សារភាព។ អ្វីទាំងអស់ ចាប់ផ្តើមពីភាពបរិសុទ្ធត្រឹមត្រូវ តែបញ្ចប់ដោយភាពឃោរឃៅ។

16 sur maquette khmer rouge

ខ្ញុំដឹងថាខ្មែរក្រហមបានថតរូបអ្នកទោសទុក។ តើគេធ្វើបែបនេះដើម្បីអ្វី? ទុកជាភស្តុតាង? ឬដើម្បីបំពេញឯកសារ? តើខ្មែរក្រហមណាមួយជាអ្នកបានថតរូបភាពទាំងនោះ? ខ្ញុំព្យាយាមស្វែងរករូបភាពទាំងនោះ។ បើសិនខ្ញុំអាចរកវាឃើញ ខ្ញុំក៏មិនអាចបង្ហាញវាបានដែរ។

តើ រូបភាពមនុស្សស្លាប់បង្ហាញពីអ្វីទៅ? ខ្ញុំជ្រើសរើសរូបភាពយុវនារីម្នាក់ដែលមិនស្គាល់ អត្តសញ្ញាណ។ នាងជំទាស់នឹងការថតរូប ដោយប្រើខ្សែភ្នែកពេជ្ឈឃាត ហើយសម្លឹងមើលមកយើងមិនដាក់។

17 sur archives riziere

ឈាមក្រហមច្រាល ស្រោចស្រពគ្រប់វាល កម្ពុជាមាតុភូមិ ឈាមកម្មករកសិករដ៏ឧត្តម ឈាមយុទ្ធជនយុទ្ធនារីបដិវត្តន៍ ឈាមប្រែក្លាយជាកម្លាំងតស៊ូមោះមុត ឈាមរំដោះផុតពីភាពខ្ញុំគេ។

ទោះបីក្នុងភាពយន្តឃោសនាមិនបានបង្ហាញពីអំពើព្រៃផ្សៃ ខ្ញុំនៅតែឃើញពីអ្វីដែលក្មេងៗទាំងនោះកំពុងរែកពុន ជាមួយដៃ មុខមាត់ និងរាងកាយទ្រុឌទ្រោមរបស់ពួកគេ។ យុវជន កម្លាំងស្រួចនេះធ្វើការដើម្បីបំផ្លាញជីវិតខ្លួនឯង។

18 sur maquette foret

ពេលយប់ ខ្ញុំនិទានរឿងដែលខ្ញុំ ចាំពីមុនអោយគេឯងស្តាប់។ មានរឿងខ្មោច ធ្មប់ អ្នកដំណើរវង្វេងផ្លូវ ក្មេងរបិុលរប៉ូច។ ដោយហេតុនេះគេអោយខ្ញុំអោយធ្វើការនៅរោងបាយ។ ដូច្នេះខ្ញុំក៏បានហូបឆ្អាញ់។ ខ្ញុំបាននិទានរឿងអ្នកជិះអាប៉ូឡូឡើងឋានព្រះចន្ទ ដល់ជនបដិវត្តដែល ទាក់ទងគ្នា ដោយលេខ ឬអក្សរសម្ងាត់។

ឈាមក្រហមច្រាលស្រោចស្រពមាតុភូមិ តើវាអាចស្រោចស្រប់ឋានព្រះចន្ទដែរឬទេ?

ខ្ញុំយល់សប្តិឃើញដើរនៅលើឋានព្រះចន្ទដូច "នេលអាមស្រ្តង"។
ដោយជំហានស្រាលដូចក្មេងរៀនដើរ។
ជំហានខ្លីរបស់គាត់គឺស្មើជំហានយក្សរបស់មនុស្សជាតិ។

Sur maquette foret/figurine Rithy Panh

ពួកគេជាអ្នកណា? មិត្តម្នាក់សួរមកខ្ញុំ។ អ្នកដែលដើរលើឋានព្រះចន្ទមែនទេ? ជាពួកអាមេរិកាំង។ ខ្ញុំធ្លាប់បានឃើញរូបភាពនេះពីមុនមក។ ពួកអាមេរិកាំង? មិត្តកុហក មិនអាចទៅរួចទេ។ បើយើងសារភាពថា កុហក គេនឹងសម្លាប់យើងចោល។ ពាក្យថាមនុស្សជាតិ មិនមានក្នុងពាក្យឃោសនារបស់ពួកមូលធនទេ។

Sur archive/enfant qui sourit

ប៉ុន្តែវានៅទីនេះ សម្រាប់យើងដែលអត់ឃ្លាន។

ឲជយោ!មាគ៌ាបដិវត្តន៍ដ៏ភ្លឺស្វាងនៃកម្ពុជាប្រជាធិបតេយ្យà។

ឲជយោ!អង្គការមហាភ្លឺស្វាង មហាអស្ចារ្យà។

19 sur maquette Rithy Panh et les buffles

នៅឋានព្រះចន្ទ គ្មានអ្វីក្រៅពីដីបែកក្រហែង និងល្អងធូលីដែលលាក់បាំងរឿងគ្រប់យ៉ាង។ ខ្ញុំត្រូវប្រើពេលរាប់ឆ្នាំ រៀនដើរដោយបាតជើងទទេ លើបន្លា។

ទឹកថ្លុកហូរចូលក្នុងបំពង់កខ្ញុំ។ ខ្ញុំបាត់រូបរាងបន្តិចម្តងៗ។ ខ្ញុំលែងមានជីវិតហើយ។

មិនគួរអោយជឿដែលមនុស្សផឹកទឹកថ្លុក។ សត្វក្របីសម្លឹងមើលយើង។ វាគិតថា ពួកមនុស្សទាំងនេះចម្លែកមែន មកផឹកទឹកថ្លុករបស់យើង។

20 sur boite ration

កំប៉ុងទឹកដោះគោជា រង្វាល់សម្រាប់អង្ករ។ មួយកំប៉ុងមានទម្ងន់ប្រហែលពីរខាំកន្លះ។ មិនយូរ ភាពអត់ឃ្លានក៏ឈ្នះគ្រប់កន្លែង។ ដំបូងឡើយ អង្ករមួយកំប៉ុងសម្រាប់មនុស្សប្រាំពីរនាក់ក្នុងមួយថ្ងៃ ក្រោយមក សម្រាប់ដប់ប្រាំមួយនាក់ រួចក៏ម្ភៃប្រាំនាក់។ យើងចែក ការអត់ឃ្លានអោយគ្នា។

ម្តាយខ្ញុំធ្វើគ្រប់យ៉ាងដើម្បីកូនៗ។ គាត់សង់ខ្ទមដោយប្រើមែកឈើ ស្លឹកឈើ និងវល្លិ៍។ រាល់ថ្ងៃ គាត់ដើរពីរម៉ោង ទៅរកទឹកស្អាតមកអោយកូនផឹក។

21 sur maquette interieur cabane

ម្តាយខ្ញុំត្រូវបានគេអនុញ្ញាត យករបបពាក់កណ្តាល អោយឪពុកខ្ញុំ។ ប៉ុន្តែល្ងាចមួយ ឪពុកខ្ញុំនិយាយថាៈ ៖ខ្ញុំមិនចង់ហូបចំណីសត្វទៀតទេ។ អត់ដាច់ខាត។ ខ្ញុំជាមនុស្ស៉។ ឪពុកខ្ញុំក៏ចាប់បង្អត់អាហារខ្លួនឯង។ ខ្ញុំមិនយល់សោះ ខ្ញុំខឹងគាត់ណាស់។

22 sur maquette du village

ពួកខ្មែរក្រហមយកបន្ទះស័ង្កសីមកសែងសាកសពគាត់យកទៅរណ្តៅ។ ម្តាយខ្ញុំមិនស្រក់ទឹកភ្នែក នៅចំពោះខ្មែរក្រហមទេ។

នៅយប់នោះ ម្តាយខ្ញុំបាននិយាយប្រាប់ខ្ញុំថា សាកសពឪពុកខ្ញុំគួរតែត្រូវបញ្ចុះដោយក្រុមគ្រួសារ មិត្តភ័ក្តិរួមអាជីព តាមប្រពៃណី

ដើម្បីអោយវិញ្ញានក្ខន្ធគាត់បានទៅកាន់សុគតិភព។ ពាក្យសម្តីរបស់គាត់ខ្ញុំចាំមិនភ្លេច វាជាស់តឿនអោយយើងតស៊ូដើម្បីរស់ ។

23 sur maquette maison de Rithy/ enfants etudiant

ឪពុកខ្ញុំមកពីគ្រួសារក្រខ្សត់។ គាត់ជឿលើការរៀនសូត្រ។ សាលារៀនជាសុបិន្តរបស់គាត់ សំរាប់គ្រួសារទាំងមូល គាត់មិនបោះបង់ចោលពួកយើងទេ គឺគាត់បានបង្រៀនយើងអោយស្គាល់ពីសេរីភាព។ ខ្ញុំមានអារម្មណ៍ថា ព្រលឹងគាត់បានត្រឡប់ទៅផ្ទះយើងវិញ ហើយសូត្រកំណាព្យរបស់កវីប្រេវ ដែលគាត់ស្រលាញ់ចូលចិត្តយ៉ាងខ្លាំង ៖ ßសក់ខ្មៅរលោង ប្រលែងលេងនឹងទឹករលក សក់ខ្មៅរលោង ផាយផាត់តាមវាយោá à។

24 sur archve tuol sleng

សាលារៀននេះក្លាយជាវាលពិឃាត។ ឥឡូវសត្វជ្រូកជាអ្នកអាន ព្រោះអ្នកអានពីមុនជាសត្វជ្រូក។

ទីនេះ ទាហានខ្មែរក្រហម មានស្លាបប៉ាកាម្នាក់មួយក្នុងហោប៉ៅ។ ពេលខ្លះមាននាឡិកាដៃទៀតផង។

វាជាសញ្ញាបង្ហាញពីឋានៈរបស់អ្នកដែលប្រើ នៅក្នុងសង្គមមួយដែលស្អប់ខ្ពើមចំណេះដឹង យើងវិញគ្មានសិទ្ធិទេ ßចបជីកជាស្លាបប៉ាការបស់មិត្ត!à។ ßដីស្រែជាក្រដាសសរសេរ!à។

25 sur archives ecole

ßនេះជាសាលាអគ្គិសនីអនុវត្តន៍ជាក់ស្តែង។ សម្រាប់បង្រៀនអ្នកបច្ចេកទេស។ សិស្សនៅទីនេះដាច់ខាតត្រូវតែជាក្មេងដែលមកពីគ្រួសារកសិករក្រខ្សត់ មកពីវណ្ណៈថ្នាក់ក្រោម ឬជាយុទ្ធជនយុទ្ធនារីចេញពីកងទ័ពបដិវត្តន៍។ មិត្តថនមានអាយុ១៦ឆ្នាំ។ ចូលបម្រើបដិវត្តន៍ និងទ័ពបដិវត្តន៍នៅអាយុ៩ឆ្នាំ។ មិត្តថនបានតស៊ូប្រយុទ្ធក្នុងសមរភូមិជាច្រើន

ហើយមិត្តក៏ធ្លាប់មានរបួសទៀតផង។ ក្មេងៗដូចជាមិត្តថនមានមិនតិចទេ។
នៅសមរភូមិមុខក៏ដូចជាសមរភូមិក្រោយ ពួកមិត្តៗមានចំនួនច្រើនរាប់មិនអស់។
មិត្តទាំងនោះមានជីវប្រវត្តិល្អណាស់។

បច្ចុប្បន្ន ពួកមិត្តខិតខំធ្វើការយកអស់កម្លាំងកាយចិត្តដើម្បីការពារ និងកសាងប្រទេសà។

26 sur maquette studio

កាលពីក្មេង ខ្ញុំចូលចិត្តទៅស្ទូឌីយោរបស់អ្នកជិតខាងម្នាក់ ដែលជាអ្នកថតកុន។

ខ្ញុំចូលចិត្តរឿង វេទមន្ត និងសំលៀកបំពាក់ គ្រឿងអលង្ការភ្លឺចិញ្ចាចរបស់តួ។ រឿងយក្ស
និងរឿងនិទាន ខ្ញុំចូលចិត្តទាំងអស់នេះ ព្រោះមានតួស្រីស្អាតៗ
មើលទៅហាក់ដូចជាពួកនាងរាំអោយខ្ញុំមើល។

27 sur danseuse

ខ្ញុំរើសហ្វីលចាស់ៗមកបញ្ចាំងមើលក្នុងប្រអប់ ដែលមានតែរន្ធតូចមួយសម្រាប់អោយពន្លឺចូល។

ក្រោយមកពិភពមួយនេះត្រូវបានកំទេច។ រោងកុននានាត្រូវបិទទ្វារ

សិល្បករត្រូវបានសម្លាប់ អ្នកចម្រៀង អ្នកបច្ចេកទេស អ្នកថតកុនត្រូវបញ្ជូនអោយទៅធ្វើស្រែ។

រឿងកុនរបស់ខ្មែរក្រហមសុទ្ធតែជារឿងឃោសនា។

ßការអនុវត្តន៍ប្រសើរជាងទ្រឹស្តី។ ដូច្នេះចូរមិត្តកុំមានគំនិតស្ងួនតួ! à។
ßមិត្តណាមានជម្ងឺពីសង្គមចាស់ត្រូវយកលេនីនធ្វើជាថ្នាំព្យាបាល!à។
មានតួអង្គតែមួយគត់ មិនមែនប្រជាជនទេ គឺប៉ុល ពត ដែលជាបដិវត្តន៍
និងត្រូវបង្កើតទេវកថារបស់ខ្លួន។

ខ្ទមមួយត្រូវបានសង់នៅកណ្តាលព្រៃ លម្អដោយរុក្ខជាតិ។

ប៉ុល ពត ជាជនបដិវត្តន៍ ផឹក ទឹកតែ ។ ប៉ុល ពត ប្រើចង្កៀងប្រេងកាត និងងូតទឹកស្ទឹង។

ក្នុងពិភពរបស់គេគឺការរស់ ជាមួយសៀវភៅ អាវុធ និងមិត្តរួមក្រុមរបស់គេ។

ហើយពេញដោយមនោគមវិជ្ជា។

បងធំទីមួយរស់នៅតាមរបៀបជនជាតិភាគតិច ចារ៉ាយ គួយ និងព្នង។
ជាបណ្តុំគ្រួសារតូចៗរស់នៅជារបបរួម ។

ប៉ុល ពតសង្កេតលើការរស់នៅរបៀបនេះ ហើយយល់ពីអ្វីដែលត្រូវធ្វើ។

ភ្ជាប់ទៅទេវកថា ស្តីពីមនុស្សរស់នៅជាមួយធម្មជាតិ របស់អ្នកនិពន្ធជនជាតិបារាំង រូសូ
ទៅដល់ប៉ារីស ប៉ុល ពត បានសរសេរអត្ថបទជាច្រើនពី កំណើតខ្មែរ។

ខ្មែរក្រហមគឺម៉ាក្ស  លេនីន និងរូសូ។

ជារបបកុម្មុយនីស្តទាំងស្រុង ដែលគេហៅថា សង្គមល្អឥតខ្ចោះ។

28 archives de combatttants KR

ឧបដិវត្តន៍ភ្លឺស្វាង ចែងចាំងត្រចះត្រចង់!។ កសិករ ធ្លាប់ត្រូវគេមើលងាយ
ត្រូវសង្គមបោះបង់ចោល ចូលរួមប្រយុទ្ធដើម្បីយុត្តិធម៌à។

សំរាប់របបថ្មី ក្រដាសប្រាក់ថ្មី ត្រូវបានបោះពុម្ភ ដោយមានរូបភាពកសិករ
ប៉ុន្តែគេមិនដែលចាយក្រដាសប្រាក់នោះឡើយ។

29 sur billet de banque dans les rues

ឧបំបាត់អោយអស់ការលក់ដូរ ការដោះដូរ ការប្តឹងផ្តល់ អំពើលួចឆក់ប្លន់
កម្មសិទ្ធិបុគ្គលស្ងួនតួ!à។ មានន័យថាលែងមានបញ្ហា។

ប្រជាជនថ្មីត្រូវលត់ដំ នៅលើក្ដីស្រែ ត្រលប់ទៅឆ្នាំសូន្យវិញ ដែលជាយុគសម័យស្អាតស្អំ។ ត្រូវតែលត់ដំប្រជាជនអោយរស់ដូចយុគសម័យ ឬត្រូវតែកំទេចចោល។

ប៉ុល ពត និយាយថា មនុស្សណាដែលអង្គការមិនអាចកសាងបាន ត្រូវចាត់ទុកជាខ្មាំង។

ឥអង្គការមិនប្រើរបស់សល់ពីកំអែលចក្រពត្តិ ឬសក្តិភូមិទ្បើយà។ រថយន្តរបស់ពួកមូលធនក៏ត្រូវការកសាងខ្លួនដែរ។

រថយន្តទាំងនោះត្រូវធ្វើការកសាងសង្គមថ្មី។

រាល់ល្ងាច នៅពេលត្រឡប់ពីធ្វើការវិញ គឺដល់វេនប្រជុំរៀនសូត្រ។ ពាក្យសំដីត្រូវបានដូរ។ ពាក្យស្លោកជាភាសានិយាយរបស់យើង។

ឥមិត្តណាមានកំហុសច្រើនគឺជាខ្មាំង! à។

ឥមិត្តណាតវ៉ាគឺជាខ្មាំង។ មិត្តណាប្រឆាំងអង្គការត្រូវកំទេចចោល! à។ ក្មេងម្នាក់អាយុ៩ឆ្នាំបានចង្អុលម្ដាយខ្លួនឯងថាបានលួចបេះផ្លែស្វាយ។ វាស្រែកថា: ឥមិត្តម្នាក់នេះបានសារភាពទទួលស្គាល់ទោសកំហុស!à។ ម្ដាយវាយំ និងសារភាពថា ព្រមទទួលការស្លាប់ដើម្បីភាពយុត្តិធម៌របស់បដិវត្តន៍។ នៅពេលដែលមនុស្សមានសេរីភាព និងសមភាពកំរិតនេះ តើ ភាពជាមនុស្ស នៅមានដែរឬទេ? ម្ដាយបិទភ្នែក។ បិទភ្នែក ដើម្បីរក្សារូបភាពរបស់កូនគាត់? គាត់មិននិយាយអ្វីទាំងអស់ រួច ដើរសំដៅទៅព្រៃ ជាមួយឈ្លប។ គាត់ មិនបានត្រលប់មកវិញជារឿងរហូត។

30 sur maquette foret

ខ្ញុំចង់រត់គេចពីភក់ជ្រាំ ភាពអត់ឃ្លាន ពីខោអាវខ្មៅរបស់ខ្ញុំ។

ខ្ញុំដើរក្នុងទឹកទាំងលំបាក ខ្ញុំដួលដោយការហេវហត់។

ពេលខ្លះខ្ញុំឃើញយន្តហោះឆ្លងកាត់ផ្ទៃមេឃ។

គេឃើញយើងទេ? គេទម្លាក់ម៉ាស៊ីនថតអោយមកខ្ញុំទេ?

ដើម្បីអោយពិភពលោកទាំងមូលបានដឹងឮ? រូបភាពដែលខ្វះគឺយើង។

យន្តហោះក្នុងក្តីស្រមៃ បានជួយស្រោចស្រង់ជីវិតខ្ញុំ។ ខ្ញុំលែងមានឈ្មោះ លែងមានគ្រួសារ លែងមានក្តីសង្ឃឹម តែខ្ញុំនៅមានបេះដូងជាមនុស្ស។

31 sur disparition du frere

ខ្ញុំនឹកដល់សម័យមុន នឹកទៅដល់បងប្រុសដែលបានបាត់ខ្លួននៅភ្នំពេញ ថ្ងៃទី១៧ មេសា ឆ្នាំ៧៥បាត់ទៅជាមួយនឹងហ្គីតារបស់គាត់។ ខ្មែរក្រហម ប្រាកដជាស្អប់គាត់ មិនចូលចិត្តក្រសៃភ្នែក សម្លេង និងចម្រៀងរបស់គាត់ទេ។

32 sur archives chantier

ពណ៌ សំណើច របាំ និងចម្រៀងត្រូវបាត់អស់ ជីវិតប្រចាំថ្ងៃរបស់យើង ជាការប្រយុទ្ធ ជាសង្គ្រាមប្រឆាំងនឹងធម្មជាតិ ប្រឆាំងនឹងពាក្យពេចន៍ ប្រឆាំងនឹងសត្រូវ។

«មិត្តកុមារដែលអង្គការបញ្ជូនទៅសមរភូមិមុខនៅតូចនៅឡើយ តែពួកមិត្តមានកម្លាំងបរិបូរណ៍ដើម្បីបំពេញកាតព្វកិច្ចរបស់ខ្លួន!»។

ខ្ញុំសូត្រតាមគេ៖ «អង្គការមិនដែលច្រឡំ អង្គការភ្នែកម្នាស់»។

33 sur archives enfants

ខ្ញុំមិនចង់អោយអ្នកណាម្នាក់ឃើញរូបភាពកូនក្មេងស្លាប់ ជើង និងមុខហើមស្គុល ដែលមើលទៅរាងកាយទាំងមូលគ្មានអ្វីក្រៅពីទឹក ។

33 sur sequence mort de la niece

ស្រីក្មេងឃ្លានទ្បើងញ័រខ្លួន។ វា ដាច់ចិត្តលួចបេះផ្លែពោតហូប។

ឈ្លបឃើញទាន់ក៏នាំវាមកផ្ទះយើង។ ទង្វើនេះ គឺជាបទឧក្រិដ្ឋ។ ជីដូនខ្ញុំហាមវាមិនអោយហូបផ្លែពោតនេះទេ។ យើងមិនត្រូវការឡើយ។ យើងនៅមានអំណួត។ នាងយំ ហើយខ្ញុំលែងយល់អ្វីទាំងអស់។

នៅពេលយប់ វាំទ៣ រគ្រាប់អំបិល ធ្មេញវាសង្កៀតក្រឹតៗ។ ពេលយប់ជាពេលស្រេកឃ្លាន។ ក្មេងស្រីនោះដេកក្បែរខ្ញុំ ពោះវាហើមធំ ភ្នែកបញ្ឈរ វាចាប់ផ្តើមដកចង្ការមាន់។

វាស្រែករកម្តាយ រកឪពុក រួចក៏បាត់មាត់ឈឹង។ គ្រួសារខ្ញុំបានបញ្ចុះសាកសពក្មេងស្រីនោះ។ ក្រោយមកបន្តិច ក្មេងពីរនាក់ទៀតក៏ស្លាប់យ៉ាងទាន់ហន់ដែរ។

ខ្ញុំមិនចង់ឃើញរូបភាពនេះទៀតទេ រូបភាពអត់ឃ្លាន រូបភាពឈឺចាប់។

តែខ្ញុំចង់អោយអ្នកដឹង។

35 sur sequence de la mort de la mere

ម្តាយខ្ញុំត្រូវបញ្ជូនទៅមន្ទីរពេទ្យ។ គាត់ឮថាកូនស្រីគាត់អាយុ១៦ឆ្នាំស្លាប់បាត់ទៅហើយ។

ទីនេះ មនុស្សស្លាប់បន្តគ្នា។ គាត់យកដៃអង្អែលថ្ងាសកូនស្រី ដោយគ្មានពាក្យមួយម៉ាត់។ គាត់ចាប់ចៃនៅលើមុខដ៏ស្គមស្គាំង។ បន្ទាប់មក គាត់ក៏ដេកស្តូកស្តឹងនៅលើក្តារ។

អង្គការហាមមិនអោយចាប់ត្រី នៅពេលដែលនៅក្នុងទឹកត្រីមានរាប់រយក្បាល។ ខ្ញុំលួចចាប់ត្រីបានមួយ។ ពីរថ្ងៃក្រោយមក ខ្ញុំក៏យកត្រីនោះ ទៅអោយម្តាយខ្ញុំ។ ប៉ុន្តែ ពេលទៅដល់ គាត់បានស្លាប់បាត់ទៅហើយ។ ពីពេលនោះមក ខ្ញុំដឹង ខ្ញុំត្រូវរស់ឯកកោរម្នាក់ឯង។

ខ្ញុំស្រមៃទៅដល់ផ្ទះយើងនៅភ្នំពេញ មានផ្ទះបាយ សួនច្បារ សៀវភៅសរសេរ ស្រមៃឃើញមុខរបស់ឪពុកម្តាយ ខ្ញុំ។ រូបភាពទាំងនេះមិនបាត់ទេ វានៅជាប់ នឹងខ្ញុំ។

36 sur archives chantier

ឲយើងខ្ញុំសូមប្ដេជ្ញាបំពេញកាតព្វកិច្ចនយោបាយឆ្នាំ១៩៧៧ ដោយដើរតាមមាគ៌ាមហាអស្ចារ្យមហាលោតផ្លោះ!à។ ខ្ញុំក្លាយជាក្មេងម្នាក់ក្នុងចំណោមក្មេងទាំងនេះនៅការដ្ឋានការងារ។ ពិនិត្យមើលរូបនេះអោយច្បាស់ទៅ យើងនឹងឃើញភាពហត់នឿយ បាក់កំលាំង មុខស្គាំងស្គម ឃើញភាពសាហាវយង់ឃ្នង។

ក្មេងមួយចំនួនមិនអាចធ្វើការទៀតទេ។ ប៉ុន្តែ មានម៉ាស៊ីនថតកំពុងថតពួកក្មេងទាំងនោះ។ រូបនេះគឺជាគ្រូរបស់យើង។ គ្រូរបស់យើងគឺ ចបជីក និងបង្គី ហើយបង្រៀនយើងពីមនោគមវិជ្ជា។

37 sur maquette enfants

ឲយើងទាំងអស់គ្នារស់នៅដោយស្មើរភាពគ្នា!à។ គឺជាបដិវត្តន៍របស់ក្មេងៗ។ យើងជាកុមារ យើងមិនសប្បាយចិត្តទ្បើយ។ ពិតហើយឲម្នាក់ៗត្រូវរស់ដោយខ្លួនទីពឹងខ្លួន!à។ ប៉ុន្តែ កម្មាភិបាលខ្មែរក្រហមហូបឆ្អាញ់ជាងយើង។ កម្មាភិបាលខ្មែរក្រហម មិនដែលស្គាល់ភាពអត់ឃ្លានទ្បើយ។ តើភាពស្មើគ្នានៅឯណា? ពេលនោះ មេៗរបស់ពួកយើងទ្បើងធ្វើស្វ័យតិះទៀន។ ស្អែកទ្បើង មិត្តខ្ញុំ និងខ្ញុំត្រូវអង្គការបញ្ជូនអោយទៅធ្វើការធ្ងន់ៗនៅការដ្ឋានផ្សេង។

នៅការដ្ឋាននេះ យើងត្រូវជីកដីអោយបានបីម៉ែត្រគីបនៅពេលព្រឹក ពេលថ្ងៃរសៀលត្រូវធ្វើដីអោយបានពី២៥ ទៅ៣០គីឡូ ដោយប្រើស្លឹកឈើ និងអាចម៍គោ។ សត្វគោមានតិចមែនទែន ចំណែកឯដើមឈើ ស្លឹកឈើរឹតតែខ្សត់ទៅទៀត។ យើងមិនអាចសម្រេចតាមផែនការបានទ្បើយ។ បើយើងមិនអាចជីកដីអោយបានបីម៉ែត្រគីបទេ នោះបទបញ្ជានឹងទ្បើងដល់ប្រាំម៉ែត្រគីប។ ឲខំធ្វើការអោយក្បៀវក្លាទ្បើង! មិនត្រូវចុះចាញ់សត្រូវទ្បើយ! មិត្តត្រូវស្រឡាញ់ និងគោរពសមូហភាព!à។ ការដ្ឋានមួយនេះគឺជាផ្ទះខ្មោចដែលយាមដោយបុរសពាក់មួកសំបុក។ ភ្នែករបស់គេសម្លឹងមើលមកយើង មិនដឹងជាវាចង់ធ្វើអ្វីទេ។ បុរសម្នាក់នេះវាយក្មេងណាដែលមិនគោរពតាមច្បាប់របស់គេ។

គេហាមយើងមិនអោយជីករកមើមឈើហូប ហាមមិនអោយនិយាយគ្នា។ ឯគេវិញហូបបាយផ្ទាល់ខ្លួនតែម្នាក់ឯង។ សត្វឆ្កែក៏មានរបបស៊ីរបស់វាដែរ។ ចំណែកឯយើង ត្រូវចែករបបគ្នាហូប។ នៅទីក្រុងប៉ារីស ឬនៅទីក្រុងផ្សេងៗ អ្នកដែលពេញចិត្តពាក្យស្លោករបស់យើង អ្នកដែលអានសៀវភៅ តើគេបានឃើញរូបភាពទាំងអស់នេះទេ? ឬមួយរូបភាពទាំងនេះមិនមានទេ?

38 sur figurine rithy

ខ្ញុំក្រឡេកមើលទៅអតីតកាល នឹកទៅដល់បងប្អូន ដែលបានស្លាប់ មានបងប្អូនប្រុសស្រីរបស់ខ្ញុំ បងប្អូនជីដូនមួយ និងម្តាយឪពុកខ្ញុំ។ កុមារភាពរបស់ខ្ញុំ ថានៅឆ្ងាយក៏ដូចជានៅជិតខ្លួន។ កុមារភាពពោរពេញទៅដោយភាពផ្អែមល្ហែម ស្រែកសប្បាយក្អាកក្អាយ។ កុមារភាពគឺជាចម្រៀងបន្ទរ។

39 sur des mains qui dessinent ma maison

ចាប់តាំងពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំមិនដែលត្រឡប់ទៅផ្ទះរបស់ខ្ញុំវិញទេ។ ប៉ុន្តែខ្ញុំនៅចងចាំគ្រប់កន្លែងទាំងអស់។ ដូចជាផ្ទាំងគំនូរ ទ្វារ ពាងទឹក របៀងផ្ទះ។

ផ្ទះខ្ញុំក្លាយជាផ្ទះល្បែង ខារ៉ាអូខេ មុននឹងក្លាយជាផ្ទះបន។ ផ្ទះរបស់ខ្ញុំសល់តែសម្បកបាត់អស់ស្លាកស្នាមអនុស្សាវរីយ៍។

គ្មានការពិតទេ មានតែរឿងកុន។ បដិវត្តន៍គឺជារឿងកុន។

Sur archives pano champagne inondee

ខ្ញុំនៅចាំទឹកជំនន់ធំនៅឆ្នាំ១៩៧៨។ កាលនោះ ខ្ញុំនៅក្នុងការដ្ឋានការងារ ហើយពួកយើងឃ្លានមែនទែន។ ស្រាប់តែមានចំបើងមួយពំនូកហូរតាមទឹកមក មានទាំងពងមាន់នៅក្នុងនោះផង។ យើងក៏បានហូបវា។

41 sur archives recolte du riz

នៅក្នុងរឿងកុន សកម្មភាពប្រមូលផលមានភាពអធឹកអធមត្រចះត្រចង់។ គេឃើញគ្រាប់ស្រូវ ទឹកមុខអ្នកប្រមូលផលស្ងប់ស្ងាត់ និងម៉ឹងម៉ាត់ មើលទៅដូចជាគំនូរ ឬកំណាព្យ។

ទីបំផុត ខ្ញុំមើលឃើញថា បដិវត្តន៍ដែលគេសន្យានោះគឺមានតែរូបភាពប៉ុណ្ណោះ។

42 sur archives khmere rouge

បាវស្រូវទាំងអស់នេះមិនមែនសម្រាប់យើងទេ។ ដូច្នេះមានតែសម្រាប់មេដឹកនាំ?
ឬសម្រាប់នាំចេញទៅបរទេស?
ព្រោះឃើញមានសរសេរជាអក្សរដូចរូបដើមឈើនៅលើបាវស្រូវ។
ឬក៏បាវស្រូវទាំងនោះគ្រាន់តែជាឆាកលម្អសម្រាប់ថតកុន ដែលតាមពិតគឺជាបាវខ្សាច់ទេ?
រាល់កាយវិការរបស់យើង រាល់ដង្ហើមចេញចូលគឺត្រូវគេឃ្លាំមើលរហូត សូម្បីតែយើងនៅស្ងៀម មិននិយាយស្តីអ្វីក៏ដោយ។ ប៉ុន្តែការអត់ឃ្លានមិនមានចំពោះមេដឹកនាំខ្មែរក្រហមទេ។
តើពួកមេដឹកនាំមិនបានឃើញ មិនបានដឹង មិនបានឮអ្វីទាំងអស់ឬយ៉ាងណា?
ឬគេមិនអាចធ្វើបាន? តើការពិតស្ថិតនៅក្នុងពាក្យស្លោកដ៏មហារុងរឿងឬយ៉ាងម៉េច?
ឬក៏ស្ថិតក្នុងរូបភាពទាំងនេះ?

43 sur discours de Pol Pot

នេះជាសម្តីរបស់ប៉ុល ពត៖ «បច្ចុប្បន្ន សហករណ៍យើងគឺជាកងសមូហភាពដ៏រឹងមាំ ទាំងនយោបាយ ទាំងស្មារតី គឺអាចសម្រេចគ្រប់ផែនការរបស់អង្គការ។ នៅគ្រប់ភូមិស្រុក សហករណ៍បានបំពេញកាតព្វកិច្ចបដិវត្តន៍ប្រកបដោយជោគជ័យ។
សហករណ៍បានផ្លាស់ប្តូរតំបន់ស្ងួតហួតហែងដ៏កម្សត់ គ្មានទឹកហូបកាលពីសម័យមុន អោយក្លាយជាអាងទឹកតូចធំ ក្លាយជាប្រឡាយទឹកហូរខ្វាត់ខ្វែង ក្លាយជាដីស្រែខៀវស្រងាត់។
សហករណ៍ជាអ្នកបង្កើតសង្គមថ្មី បរិសុទ្ធ បំបាត់អំពើពុករលួយ ឬពាលាអាវ៉ាសែ។

សហករណ៍បង្កើតសង្គមថ្មី សមូហភាព គ្មានអំពើពុករលួយ មានតែសមភាព និងភាពរុងរឿង។ សហករណ៍រស់នៅហូបចុកគ្រប់គ្រាន់ ប្រកបដោយសុខភាពបរិបូរ អនាម័យត្រឹមត្រូវ ទទួលបានការអប់រំ រៀនសូត្រ និងចំណេះដឹងខាងផ្នែកវប្បធម៌à។ ចំណែកឯការពិតនោះគឺ លំនៅដ្ឋានធ្វើពីចំបើង ការរាំងស្ងួត ការនឿយហត់ ការអត់ឃ្លាន អំពូលម៉ែត្របើកបំភ្លឺអោយយើងធ្វើការពេលយប់។ មេក្រូបំពងសម្លេងក្តែងៗផ្សាយពីពាក្យស្លោក។ មនោគមវិជ្ជាជ្រួតជ្រាបតាមស្រែចម្ការ។

44 sur archives chantier

រូបភាពឃើតៗ និងការពិតទាំងនេះថតដោយអង់ សារុន។ គាត់ជាអ្នកថតកុនខ្មែរក្រហម។ រូបប៉ុល ពត ថ្លែងសុន្ទរកថាក៏ជាស្នាដៃរបស់អង់ សារុនដែរ។ ហេតុអ្វីក៏មា នពុ្នរីបណ៌សនេញរូបភា ពយ៉ា ងនេះ? ជាកំហុសបច្ចេកទេស? ឬក៏អ្នកថតចង់បង្ហាញពីខោអាវរយ៉េរយ៉ៃរបស់ក្មេងៗ? ចង់បង្ហាញអោយបងធំទីមួយឃើញពីស្ថានភាពស្រុកទេស? អ្នកថតរូបនេះត្រូវគេធ្វើទារុណកម្ម រួចសម្លាប់ចោល។ សាកសព ប្រវត្តិរបស់គាត់រលាយបាត់មែន ប៉ុន្តែហ្វីលកុនរបស់គាត់មិនបាត់ឡើយ។

45 sur archives Pol Pot

ឧបេ្តជ្ញាជ្រោងទង់បដិវត្តន៍អោយខ្ពស់ត្រដែតត្រដឹម!à។ យើងមានអារម្មណ៍ថាសម្ដីនេះដូចសម្ដីរបស់ម៉ៅ សេទុង។ គឺជាពាក្យស្លោករបស់ខ្មែរក្រហម។ ប៉ុល ពត ធ្វើដំណើរទៅព្រលានយន្តហោះដើម្បីទទួលគណៈប្រតិភូជាន់ខ្ពស់ចិនពីររូប។ គឺហ្សាង ឈុនយ៉ាវ និងកេង ប៊ីវ។ សមមិត្តចិនជះឥទ្ធិពលទៅលើនយោបាយ និងមនោគមវិជ្ជារបស់កម្ពុជាប្រជាធិបតេយ្យ។ រូបភាពចំណងមិត្តភាពនេះមិនបាត់ឡើយ។ អង្គការមហាលោតផ្លោះពិតជាអស្ចារ្យមែនទេ? ថ្ងៃណាក៏ជាថ្ងៃបុណ្យដែរមែនទេ?

របបកម្ពុជាប្រជាធិបតេយ្យកំពុងឈានទៅរកភាពជោគជ័យមែនទេ?
តាមរយៈភាពបរិសុទ្ធស្អាតស្អំ ភាពទទេស្អាត ដែលជាគន្លងផ្លូវរបស់បដិវត្តន៍ចិន
ជាបដិវត្តន៍ដែលទទួលបរាជ័យនៅប្រទេសចិន?
របបកម្ពុជាប្រជាធិបតេយ្យគឺជាមន្ទីរពិសោធន៍មនោគមវិជ្ជាដ៏អស្ចារ្យមែនទេ?
ដំណើរទស្សនកិច្ចនេះគឺជាមេរៀនមួយឬយ៉ាងដូចម្តេច?

46 sur maquette de rithy

យើងដើរចាប់កណ្តុរហូប។ យើងហូបសត្វល្អិត ហូបរឹសឈើ ហូបខ្យងទាំងនៅឆៅ។
ពេលនេះហើយដែលធាតុជាមនុស្សរបស់យើងចាប់ផ្តើមបាត់បង់ ដោយសារតែការស្រេកឃ្លាន
ជម្ងឺ និងរាងកាយចុះទ្រុឌទ្រោម។

47 sur mains du sculpteur

អ្នកណាថតប្រជាជនឈឺ? អ្នកណាថតវត្តអារាមដែលក្លាយជាមន្ទីរពេទ្យ?
ហើយចុះម្នាក់ដែលដេកនៅគ្រែក្បែរខ្ញុំ ជង្គង់មានដង្កូវវារវាមនេះវិញ? ចំណែក
ស្ត្រីម្នាក់នេះដែលឆ្លងទន្លេមិនរួច ស្រែកពេញមួយយប់តែម្នាក់ឯង
យកដៃវាយតប់ពោះរហូតដល់ដាច់ខ្យល់ អ្នកណាថត?

48 sur maquette hospital KR

ពិតណាស់ថា មានមន្ទីរពេទ្យខ្មែរក្រហម។ ខ្ញុំធ្លាប់រស់នៅទីនោះរាប់អាទិត្យ
នៅក្នុងបន្ទប់ខ្មោចដ៏ធំនេះ។ គេដាក់ថ្នាំពេទ្យនៅក្នុងដបទឹកក្រូច កូកាកូឡា។
គេយកទឹកដូងធ្វើជាថ្នាំចាក់។

បើអាចទៅរួច ខ្ញុំមិនចង់ឮសម្លេងថ្ងូរ សម្លេងដកចង្ការមាន់ ស្រែកឈឺចាប់នោះទេ។
ខ្ញុំលែងចង់ធុំក្លិនដំបៅស្អុយរលួយទៀតហើយ។ អ្នកជម្ងឺស្លាប់នៅពេលយប់។ លុះព្រឹកឡើង
ខ្ញុំត្រូវយកសាកសពនោះចេញ។ រូបខ្ញុំនៅមានជីវិតនៅឡើយ។ បុរសនេះអង្គុយលើដី
លែងមានកម្លាំងកំហែងអ្វីទៀតហើយ។ គាត់ហូបលែងកើត កម្រើកលែងបាន។
រូបភាពគាត់នៅដក់ជាប់ក្នុងអារម្មណ៍ខ្ញុំរាប់សិបឆ្នាំ។ ខ្ញុំបោះដៃទៅរកគាត់។

49 sur archives experience medecin KR

ខ្មែរក្រហមបានកម្ទេចចោលថ្នាំរបស់ពួកមូលធន។ ខ្មែរក្រហម កាត់ឫសឈើ យកមកស្ងោរ។
ខ្មែរក្រហមយកថ្នាំបុរាណមកពិសោធដើម្បីព្យាបាលអ្នកជម្ងឺ។ ដូច្នេះហើយ
នេះជាការព្យាបាលបែបបដិវត្តន៏។មានក្រុមធ្វើពិសោធមនុស្សគ្រប់ទីកន្លែង ឧទាហរណ៍ដូចជា
មន្ទីរស២១។  លែងមានសញ្ញាប័ត្រហើយ មានតែសញ្ញាឃើញ។

50 sur maquette hopital

ខ្ញុំលាងសម្អាតបន្ទប់។ ខ្ញុំលាងសម្អាតអ្នកជម្ងឺ។ រាល់ព្រឹក ខ្ញុំសែងសាកសពរហូតដល់រណ្តៅ។
មានពេលខ្លះ ខ្ញុំមានអារម្មណ៍ហាក់ដូចនៅមាត់រណ្តៅខ្មោច។ ខ្ញុំឮសម្លេងខ្សាវៗ
សម្លេងចបទង្គិចនឹងឆ្អឹង ខ្ញុំឃើញដៃរាវចាប់រកអ្វីម្យ៉ាង ហើយដៃនោះចាប់បានដៃក្មេងម្នាក់។

ក្មេងម្នាក់នោះដែលនៅរស់ ហើយដែលកំពុងនិទានរឿងនាពេលនេះ គឺជារូបខ្ញុំ។

51 sur images

ចូលដល់វ័យពាក់កណ្តាលជីវិតមនុស្ស អនុស្សាវរីយ៍ពីក្មេង ដែលពោរពេញដោយភាពផ្អែមល្ហែម
លាយឡំនឹងភាពល្វីងជូរចត់បានលេចធ្លោឡើងវិញក្នុងការចងចាំ។
កុមារភាពគឺដូចអ្នកលង់ទឹក។ កុមារភាពគឺដូចសំណួរមួយ ដែលសួរថា
ខ្ញុំមកទីនេះដោយរបៀបណា? ហេតុអ្វីក៏ខ្ញុំមិនអាចជួយគ្រួសារខ្ញុំអោយបានច្រើន?
ជាមួយនឹងកុមារភាព មានសេចក្តីស្លាប់រួចទៅហើយ។

52 sur pellicule

យើងយល់ពីខ្មែរក្រហម តាមរយៈការសង្កេតរូបភាព។ ប៉ុល ពត ខំកែច្នៃការពិតអោយស្របនឹងបំណងរបស់ខ្លួន ពោលគឺយកឈ្នះលើធម្មជាតិ។

មានពេលខ្លះ កម្មាភិបាលខ្មែរក្រហមបានកោះប្រជុំអ្នកភូមិជាច្រើនមកមើលកុន។ គឺជារឿងកុនដែលអួតសរសើរពីការប្រយុទ្ធរបស់ប្រជាជនដែលមានតែបាតដៃទទេប្រឆាំងនឹងពួកអាណានិគមដ៏មានអំណាច។ ជាការពិត យើងដឹងថាតួសម្តែងលេងមិនសមទេ ដឹងថារឿងកុននេះមិនល្អមើល ហើយមានអ្នកមើលជាច្រើនដេកលក់ដោយសារការហត់នឿយ។ ដូចរូបខ្ញុំជាដើម។

53 sur maquette foret

ក្នុងអំឡុងពេលបួនឆ្នាំ យើងត្រូវដូរការដ្ឋានធ្វើការពីមួយទៅមួយ។ តើអោយយើងងើបតស៊ូរើបម្រះយ៉ាងដូចម្តេចបាន បើយើងមានតែខោអាវខ្មៅមួយចង្កេះ និងស្លាបព្រាបាយមួយនៅជាប់នឹងខ្លួន? ត យើ ◌ើត៏ស៊ូយ៉ា ង់មចេ ប ើយើងគ្មានទាំងសេចក្តីសង្ឃឹម ហើយពោះឃ្លានទៀតនោះ? បច្ចុប្បន្ន មានអ្នកខ្លះនិយាយថា គឺដោយសារតែពុទ្ធសាសនា និងជំនឿលើព្រហ្មលិខិត។ តើអ្នកដែលយល់ឃើញបែបនេះ ពេលនោះគេនៅឯណា? ឬពួកគេគ្រាន់តែអាននៅក្នុងសៀវភៅ? ឬក៏ជាការពិចារណាក្នុងពពក?

នៅទីនេះ មិនមែនកម្មផល ឬសាសនាទេដែលធ្វើអោយមនុស្សស្លាប់។ គឺមកពីមនោគមវិជ្ជា។ ការចាប់ផ្តើមដំបូងនៃរបបផ្តាច់ការគឺមានរឿងបោកប្រាស់ទៅហើយ។ ßបើមិត្តខ្លាចសត្រូវ មានន័យថាមិត្តខ្លាចអង្គត់ឈើà។ ខ្ញុំធ្លាប់ធ្វើការនៅក្នុងព្រៃធំៗ។ យើងទទួលបញ្ជាអោយកាប់ឆ្ការព្រៃដើម្បីដាំពោត ក្រោមកម្តៅថ្ងៃថែស។ មានសត្វពស់ សត្វអាពីង និងសត្វបង្គួយ ហើយមិត្តខ្លះហូបបង្គួយនេះ។

ßយើងមិនត្រូវចុះចាញ់ធម្មជាតិឡើយ។ យើងប្តេជ្ញាប្រយុទ្ធវាយសម្រុកយកឈ្នះសត្រូវ!à។

ពាក្យស្លោកទាំងនេះមិនបានដាស់អោយខ្ញុំភ្ញាក់ទេ
គឺសម្លេងមកពីព្រៃធំទេដែលធ្វើអោយខ្ញុំភ្ញាក់ពីដេក។

54 sur maquette foret

យើងសុំានឹងការរស់នៅក្នុងព្រៃ សុំានឹងអាកាសធាតុត្រជាក់។ ក្រោយពីភ្លៀងធ្លាក់មួយមេធំ
យើងដេកទាំងខោអាវទទឹកជោគ។

ខ្ញុំនឹកស្រមៃទៅដល់ផ្សារធំថ្មី នឹកដល់ក្លិនចម្រុះលាយឡំគ្នា ក្លិនក្រអូបនៃផ្កាម្លិះ។
ខ្ញុំនឹកស្រមៃទៅដល់គូសង្សារដែលបង្ហាញភាពអៀនប្រៀន និងកែវភ្នែករបស់គេ។
ខ្ញុំនឹកទៅដល់ភាពសំបូរបែប។ ខ្ញុំស្រមៃឃើញក្រណាត់សូត្រ ត្រី សាច់ ក្លិនឈ្ងុញនៃមាន់ស្ងោរ
ដែលខ្ញុំនឹកជាប់ក្នុងអំឡុងបួនឆ្នាំនេះ។
ខ្ញុំនឹកទៅដល់ម្ហូបអាហារដ៏ឈ្ងុយឆ្ងាញ់ជាមួយនឹងបរិយាកាសក្អាកក្អាយ។ កាលនោះ  នៅផ្សារ
មនុស្សម្នាមានមាត់ សម្រាប់សើចសប្បាយ សម្រាប់ជជែកគ្នាពីនេះពីនោះ ឬសម្រាប់ថើបគ្នា។

55 sur pano rue vide

គឺផ្លូវនេះហើយ កាលពីមុនមានសភាពអ៊ូអរ ប៉ុន្តែក្រោយមកក្លាយជាស្ងាត់ជ្រងំទទេស្អាត។
ពិតណាស់គឺពិតជាផ្លូវនេះមែន នៅម្តុំជាយក្រុងភ្នំពេញ។ គ្រាន់តែមើលក៏ដឹងដែរ។
ខ្ញុំនឹកឃើញពិភពមួយដែលមិនល្អឥតខ្ចោះ ជាពិភពដែលមានមនុស្សរស់នៅ។ ប៉ុល ពត
និយាយថាៈ ឪពីរពាន់ឆ្នាំរស់នៅខ្ញុំគេà។

56 sur maison

គេក៏ជាមនុស្ស ដូចអ្នក និងខ្ញុំដែរ  គ្រាន់តែគេបានជ្រើសរើសផ្លូវមួយ។ ជាជម្រើសមនោគមវិជ្ជា
ជា ជម្រើសដ៏ឧក្រិដ្ឋ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ពិបាកនឹងទទួលយកដែរá។
ដូច្នេះហើយទើបខ្ញុំចង់ថតរឿងនេះá។ ខ្ញុំចង់ថតរឿងនេះ ព្រោះថាគ្មានអ្នកណាម្នាក់កើតមកជា
ឃាតករពីកំណើតនោះទេ មិនមែនកើតមកá

### ឪពុក

កូនប្រុសយើងឥឡូវពូកែណាស់ខាងនិយាយរឿងឥតបានការ៖គេនិយាយប៉ប៉ាច់ប៉ប៉ោច។ ឃ្លាឃ្លោងគឺគេពូកែណាស់។

### ម្ដាយ

ឪវាឯងចង់អោយវាធ្វើគ្រូដូចឯងដែរ។ ប៉ុន្ដែ គេកំពុងតែថតរឿងរបស់យើង ថតពីយើង៖

### ឪពុក

ប៉ុន្ដែ មានអ្នកក្រអត់អីហូប អ្នកក្រត្រូវអ្នកមានបណ្ដេញចេញពីដីធ្លីរបស់ខ្លួន។ ចំណែកឯកូនយើង បែរជាគិតតែពីរឿងខ្មែរក្រហមទៅវិញ៖

Sur archive KR

ឪពុកនិយាយត្រូវ។ មុននឹងមានខ្មែរក្រហម អ្នកក្រត្រូវអ្នកមានបណ្ដេញចេញពីដីរបស់ខ្លួន។ ហេតុនេះហើយទើបខ្មែរក្រហមបានកេណ្ឌប្រជាជនដោយសារអំពើអយុត្តិធម៌នេះ។ នៅមានវត្តមានអាមេរិកាំងទៀត។
អាមេរិកាំងបានទម្លាក់គ្រាប់បែកជាងប្រាំសែនតោនមកលើប្រទេសខ្មែរ។ ដូច្នេះ អ្នកក្រក៏សម្រេចចិត្តចូលបម្រើបដិវត្តន៍។ អ្នកក្រប្ដេជ្ញាចិត្ត។
ខ្មែរក្រហមនិយាយកុហកអ្នកក្រពីរឿងយុត្តិធម៌ សមភាព សុភមង្គល រីកចម្រើន ពោលគឺកុហកគ្រប់រឿង។ អ្នកក្រដដែលនេះទីបញ្ចប់ ត្រូវមកជីកកាប់គាស់ ដីដដែលនាពេលសព្វថ្ងៃ។

58 sur maquette psy

មានពេលខ្លះខ្ញុំយល់សប្ដិឃើញក្មេងម្នាក់។ ចាត់ទុកថាក្មេងនោះគឺរូបខ្ញុំទៅចុះ។ វាមិនចេះធ្វើអ្វីទាំងអស់ មិនចេះស្លូចត្រី មិនចេះដើរជើងទទេ មិនចេះវាយតប់។

ច្រើនឆ្នាំក្រោយមក វាមានអារម្មណ៍បន្ទោសខ្លួនឯងដោយ
មិនអាចជួយអ្នកដែលអត់ឃ្លានអោយបានច្រើនជាងនេះ។
និយាយចេញមកគឺអាចធ្វើអោយយើងបានធូរចិត្តខ្លះ ធ្វើអោយយើងយល់ អោយយើងដើរឆ្លង
ផុតអតីតកាល។

សម្រាប់រូបខ្ញុំ ខ្ញុំមិនអាចធ្វើចិត្តអោយដូចគតិបណ្ឌិតបានទេ។ ខ្ញុំមិនរករូបភាពឪពុកម្ដាយខ្ញុំ
គឺខ្ញុំចង់ប៉ះពាល់ខ្លួនប្រាណពួកគាត់ផ្ទាល់។ សម្លេងឪពុកម្ដាយមិនមានឡើយ
ដូច្នេះខ្ញុំមិនចង់និយាយទេ។ ខ្ញុំចង់ចាកចេញពីអ្វីៗទាំងអស់ ខ្ញុំមិនចង់និយាយ
ខ្ញុំចង់ចាកចេញពីប្រទេសរបស់ខ្ញុំ ប៉ុន្តែជាការឥតប្រយោជន៍ទេ
ព្រោះថាកុមារភាពរបស់ខ្ញុំបានវិលត្រឡប់មករកខ្ញុំ។ ពេលនេះ
គឺកុមារម្នាក់នេះដែលព្យាយាមរកខ្ញុំ។ ខ្ញុំឃើញវា វាចង់និយាយមករកខ្ញុំ។ ប៉ុន្តែ
វាពិបាកនិយាយណាស់។

59 sur chien noir

ផ្ដៃខ្មៅមួយក្បាលនេះ គឺជាព្រះជួយសង្គ្រោះខ្ញុំ។ វាបាននាំខ្ញុំទៅដល់ទូកមួយ។
កាលណាខ្ញុំមើលវា ធ្វើអោយខ្ញុំនឹកទៅដល់បុរសពាក់មួកសំបុក
នឹកទៅដល់សាកសពដែលអណ្ដែតទឹក។

នៅភូមិដែលខ្ញុំរស់នៅពីមុន អ្នកស្រុកដែលធ្លាប់រស់នៅសម័យខ្មែរក្រហម បន្តរស់នៅទីនោះ
ក្រោយពីខ្មែរក្រហមបានរត់ចេញ។ ប្រុសៗពេញកម្លាំងបានចេញទៅធ្វើការនៅប្រទេសថៃ។
ចំណែកឯអតីតប្រធានភូមិខ្មែរក្រហម ជិះសេះ ដែលធ្លាប់តែឃោរឃៅ
និងធ្វើអោយយើងភ័យខ្លាច មិនត្រូវបានចាប់ខ្លួន ហើយនៅតែរស់នៅដោយសេរីភាព។
ខ្ញុំគិតថា ប្រធានភូមិខ្មែរក្រហមនេះ រស់នៅយ៉ាងសប្បាយ និងមានកូនចៅច្រើន។

60 sur maquette pano cantine

រោងបាយខ្មែរក្រហមបានរលាយបាត់រូប គ្មាននៅសល់អ្វីទៀយ នៅសល់តែកម្ទេចពាង ឆ្នាំងច្រេះ និងចង្រ្កានដីមួយប៉ុណ្ណោះ។ គ្រប់យ៉ាងបានកន្លងផុតទៅ ដូចនៅក្នុងរឿងកុនមួយដ៏សាហាវ។ ចំណែកឯរណ្ដៅកប់ខ្មោចនៅក្បែរមន្ទីរពេទ្យ កន្លែងដែលខ្ញុំធ្លាប់កប់ខ្មោចរាប់មិនអស់ រណ្ដៅកប់សាកសពម្ដាយខ្ញុំ បងស្រីខ្ញុំ ក្លាយជាបឹងមួយ ដែលជីកដោយអង្គការអន្តរជាតិ។ អដ្ឋិធាតុត្រូវគេជីកយកចេញ។ គេយកកន្លែងនោះដាំល្ពៅ ដាំពោត។ ប៉ុន្តែទឹកបឹងកខ្វក់ ពណ៌ខៀវ គ្មានអ្នកណាហ៊ានប្រើ ឬក៏ផឹកទៀយ។

61 sur la figurine de rithy

-អ្នកស្លាប់នៅទីនេះមែនទេ?

-មែនហើយ។ ពេលខ្លះខ្ញុំមានអារម្មណ៍ថាយើងដើរជាន់លើអ្នកស្លាប់។ ដូច្នេះខ្ញុំក៏ខំដើរចៀស។ ប៉ុន្តែ នៅតែមានព្រលឹងដែលវិលវល់ ព្រលឹងដែលស្វែងរកកន្លែងមួយ ស្វែងរកគតិដ៏ឧត្ដុងឧត្ដម។ មានមនុស្សច្រើនណាស់ដែលបានតស៊ូដោយមិននិយាយស្ដីអ្វី ឬដោយពាក្យតែមួយម៉ាត់ ដោយស្នាមញញឹម។ ពេលខ្លះ គ្រាន់តែធ្វើកាយវិការអាចមានន័យថា ទេ។ ខ្ញុំនឹកទៅដល់ឪពុករបស់ខ្ញុំដែលប្រាប់យើងពីជម្រើសរបស់គាត់។ ពេលខ្លះ ភាពស្ងៀមស្ងាត់មិននិយាយស្ដីគឺជាសម្រេក។

Sur ensevelissement repete

ទុក្ខព្រួយដោយសារមានមនុស្សស្លាប់ពិបាកទ្រាំណាស់។ មានតែការបញ្ចុះសពឥតឈប់ឈរ។ លែងមានរទេះដឹកសត្វ លែងមានពាក្យស្លោក លែងមានឈ្លបខោអាវខ្មៅទៀតហើយ។ មានតែដីដែលជ្រួតជ្រាបទៅដោយឈាម។ សាច់ឈាមរបស់ពួកគាត់គឺជាសាច់ឈាមរបស់ខ្ញុំ។ យើងរស់នៅជាមួយគ្នារហូត។ មានរឿងរ៉ាវច្រើនណាស់ដែលមនុស្សមិនគួរឃើញ ឬដឹង។ តែបើគេឃើញវិញនោះ យកល្អគេគួរតែស្លាប់ទៅវិញប្រសើរជាងនៅមើលឃើញរឿងរ៉ាវទាំងនោះ។

តែបើអ្នកណាម្នាក់ក្នុងចំណោមយើងឃើញរឿងរ៉ាវទាំងនោះ ឬក៏បានដឹងឮ ដូច្នេះមនុស្សត្រូវតែរស់ដើម្បីនិយាយរឿងនេះប្រាប់យើង។

រាល់ព្រឹក ខ្ញុំធ្វើការនៅលើរណ្តៅកប់ខ្មោច។ ចបកាប់របស់ខ្ញុំប៉ះនឹងឆ្អឹង ប៉ះនឹងលលាដ៍ក្បាលខ្មោច។ អាចម៍ដីមានមិនច្រើនទេ មានច្រើនតែឆ្អឹងខ្មោច និងលលាដ៏ក្បាល។ ថ្ងៃណាមួយគង់តែដល់វេនខ្ញុំដែលត្រូវស្លាប់។

ឬក៏អាចនិយាយបានថា រូបខ្ញុំបានស្លាប់បាត់ទៅហើយ។ ពិតណាស់ ខ្ញុំមិនអាចស្វែងរករូបភាពដែលខ្វះនោះទេ ខ្ញុំព្យាយាមរកវាដែរ តែនៅតែរកមិនឃើញ។ រឿងកុនឃោសនានយោបាយ គួរណាស់តែជីកកកាយអ្វីដែលរឿងកុននោះបានតាក់តែងឡើង។ ដូច្នេះ ខ្ញុំក៏បង្កើតរូបភាពនេះឡើង។ ខ្ញុំមើលវា។ ខ្ញុំស្រឡាញ់វា។ ខ្ញុំអោបវាទុកក្នុងរង្វង់ដៃ ប្រៀបដូចខ្ញុំក្រសោបរង្វង់មុខអ្នកដែលខ្ញុំស្រឡាញ់។ រូបភាពដែលខ្វះនេះ ពេលនេះខ្ញុំអោយទៅអ្នក ដើម្បីអោយរូបភាពនេះឈប់តាមលងយើងទៀត៕